ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា១ និងមាត្រា៣

នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦

ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញ អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រាមួយ.-**

មាត្រា១ និងមាត្រា៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា ត្រូវបានកែសម្រួល ដូចតទៅ÷

**មាត្រា ១ថ្មី.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក ✓ |
| ១១- រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិកប្រចាំការ |
| ១៧- អភិបាល នៃគណៈអភិបាលរាជធានី-ខេត្តពាក់ព័ន្ធ | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា។

**មាត្រា ៣ថ្មី.-**

គណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

ប្រធានគណៈកម្មាធិការគ្រប់គ្រងនិងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ឬអ្នកបច្ចេកទេសដទៃទៀត ចូលរួមប្រជុំ តាមការចាំបាច់។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ